# ជនផ្តាច់ការ ?

ជនផ្តាច់ការ ជាមនុស្សទន់ខ្សោយ ដោយសារធម្មជាតិ ប៉ុន្តែគាត់មានឱកាសដោយចៃដន្យ ក្លាយជាបុរសខ្លាំង។ ឱកាសនេះធ្វើអោយគាត់ ក្លាយជាជនផ្តាច់ការ ព្រោះគាត់ទុកជាភ័ព្វសំណាងអាថ៌កំបាំង ឬ បេសកកម្មទិព្វ ដែលគាត់បានទទួលពីកំណើតពីអំណាចអាទិទេព ដែលនាំឱ្យគាត់គិតថា គាត់ជាអច្ឆរិយបុគ្គល។ បើជននោះ ជាស្តេច ព្រះអង្គ ទុកខ្លួនព្រះអង្គ ជាអាទិទេព មានសិទ្ធិពេញច្បាប់។ បើជននោះ ជារាស្ត្រ គាត់ ទុកខ្លួនគាត់ជាស្តេច ដើម្បីប្រើសិទ្ធិស្តេច តាំងខ្លួនជាឧត្តមជាងអស់មនុស្ស។ នៅស្រុកខ្មែរ តាំងពីបុរាណកាលមក អស់ព្រះមហាក្សត្រ មានទសពិធរាជធម៌ ជាច្បាប់ដឹកនាំជាតិ។ បើប្រសិនជា ព្រះអង្គណាមួយ ទ្រង់បញ្ចៀសច្បាប់នោះ ប្រជារាស្ត្រនឹងទុកព្រះអង្គនោះជាស្តេចពាល ព្រោះថា រាជទង្វើនោះ វារមែងនាំទុក្ខគ្រប់បែបយ៉ាងដល់ប្រជាជាតិ។ មួយវិញទៀត អស់ជនផ្តាច់ការ តាំងខ្លួនជាស្តេច តែមិនគោរពច្បាប់រដ្ឋ មានកំហុសជាទ្វេ, ទី១ ជាកំហុសរបស់ស្តេចពាល, ទី២ ជាកំហុសរបស់ជនតិរច្ឆាន។ ស្តេចពាល ជាស្តេច បំពានច្បាប់ទំនៀមទម្លាប់របស់ព្រះអង្គ, រីឯ ជនតិរច្ឆាន ធ្វើច្បាប់សំរាប់មិនគោរពច្បាប់រដ្ឋ ដើម្បី យកវាមកបំរើ អត្ថប្រយោជន៍តិរច្ឆានរបស់ខ្លួន។ ដូច្នេះ ស្តេចពាល តែងតែការពារជនតិរច្ឆាន ក៏ដូចជាផ្ទុយទៅវិញដែរ ព្រោះជាជនបំពានច្បាប់ដូចគ្នា។ ប្រទេសណាមួយ ដែលមាន ស្តេចពាល និង ជនតិរច្ឆានផង ជានគរចង្រៃសំរាប់ប្រជារាស្ត្រ។ តើស្រុកខ្មែរ ជានគរបែបណា ?